ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ០៧ អយក. ...

# សេចក្តីណែនាំ
## ស្តីពី
## ការបង្រៀន និងរៀន ការអប់រំស្តីពីការប្រឆាំងអំពើពុករលួយ សម្រាប់កម្រិតមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ ទី១១ និងថ្នាក់ទី១២

**យោង:** - ប្រកាសលេខ៣៧៥ អយក.ប្រក. ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ ស្តីពីការអនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ ការអប់រំស្តីពីការប្រឆាំងអំពើពុករលួយ សម្រាប់គ្រូមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ ទី១១ និងថ្នាក់ទី១២។

- ប្រកាសលេខ៣៧៦ អយក.ប្រក. ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ ស្តីពីការអនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ ការអប់រំស្តីពីការប្រឆាំងអំពើពុករលួយ សម្រាប់សិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ ទី១១និងថ្នាក់ទី១២ ។

ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយអង្គភាពប្រឆាំងអំពើពុករលួយ អភិវឌ្ឍសៀវភៅ "ការអប់រំស្តីពីការប្រឆាំងអំពើពុករលួយ" សម្រាប់គ្រូ និងសិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី ១០ទី១១ និងថ្នាក់ទី១២ ដើម្បីដាក់បញ្ចូលក្នុងកម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាចំណេះទូទៅ ថ្នាក់ទី១០ ទី១១និង ថ្នាក់ទី១២។

ដើម្បីអនុវត្តកម្មវិធីសិក្សា និងប្រើប្រាស់សៀវភៅសិក្សា "ការអប់រំស្តីពី ការប្រឆាំងអំពើពុករលួយ" សម្រាប់គ្រូ និងសិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ ទី១១ និងថ្នាក់ទី១២ ឱ្យមានប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដូចតទៅ៖

### ១.ការប្រើប្រាស់សៀវភៅសិក្សា

គ្រប់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈទាំងអស់ត្រូវប្រើប្រាស់សៀវភៅ ការអប់រំស្តីពីការប្រឆាំងអំពើពុករលួយ សម្រាប់គ្រូ និងសិស្ស កម្រិតមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ ទី១១ និងថ្នាក់ទី១២ ជាសៀវភៅសិក្សា ក្នុងការរៀន និងបង្រៀននៅថ្នាក់ទី១០ ទី១១ និងថ្នាក់ទី១២ ។

### ២.ការប្រើប្រាស់ម៉ោងសិក្សា

ការបង្រៀន និងរៀនខ្លឹមសារមេរៀនការអប់រំស្តីពីការប្រឆាំងអំពើពុករលួយ ត្រូវមានការកំណត់ច្បាស់លាស់ ក្នុងម៉ោងសិក្សាមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា ថ្នាក់ទី ១០ ទី១១ និងថ្នាក់ទី១២ដោយមានពាក់ព័ន្ធចំនួន០៨ម៉ោងសិក្សាសម្រាប់កម្រិតថ្នាក់នីមួយៗ ក្នុង១ឆ្នាំសិក្សា។

### ៣.បំណែងចែកមេរៀន

សៀវភៅ ការអប់រំស្តីពីការប្រឆាំងអំពើពុករលួយសម្រាប់គ្រូក៏ដូចសៀវភៅសម្រាប់សិស្ស កម្រិតមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ ទី១១ និងថ្នាក់ទី១២ ត្រូវបានរៀបចំជាសៀវភៅមួយក្បាល។ ដូច្នេះ គ្រូត្រូវបែងចែកមេរៀនទៅតាម បំណែងចែកមេរៀនក្នុងសៀវភៅសម្រាប់គ្រូ ដូចខាងក្រោម ៖

**ថ្នាក់ទី១០**

- ឆមាសទី១៖
  - មេរៀនទី១៖ ពលរដ្ឋល្អ ស្អាតស្អំ
  - មេរៀនទី២៖ សេចក្តីត្រូវការ និងមហិច្ឆតា
- ឆមាសទី២៖
  - មេរៀនទី៣៖ គោលដៅ និង មធ្យោបាយ
  - មេរៀនទី៤៖ អ្វីជាអំពើពុករលួយ

**ថ្នាក់ទី១១**

- ឆមាសទី១៖
  - មេរៀនទី៥៖ គុណភាពជីវិត
  - មេរៀនទី៦៖ មូលហេតុ និងផលវិបាកនៃអំពើពុករលួយ
- ឆមាសទី២៖
  - មេរៀនទី៧៖ ប្រព័ន្ធផ្សព្វផ្សាយចម្រុះ និងការប្រឆាំងអំពើពុករលួយ
  - មេរៀនទី៨៖ ការប្រឆាំងអំពើពុករលួយក្នុងវិស័យឯកជន

**ថ្នាក់ទី១២**

- ឆមាសទី១៖
  - មេរៀនទី៩៖ តួនាទី-កាតព្វកិច្ចក្នុងសង្គម និងការប្តេជ្ញាចិត្ត
  - មេរៀនទី១០៖ ក្រមសីលធម៌
- ឆមាសទី២៖
  - មេរៀនទី១១៖ សិស្សចូលរួមប្រឆាំងអំពើពុករលួយ
  - មេរៀនទី១២៖ ការប្រឆាំងអំពើពុករលួយនៅកម្ពុជា

### ៤.ការរៀបចំគ្រូបង្រៀន

គណៈគ្រប់គ្រងសាលារៀននីមួយៗ ត្រូវរៀបចំគ្រូបង្រៀន មុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា ឱ្យបង្រៀន ការអប់រំស្តីពីការប្រឆាំងអំពើពុករលួយ កម្រិតមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ ទី១១ និងថ្នាក់ទី១២ ពិសេស គ្រូដែលបានទទួលការបណ្តុះបណ្តាលកន្លងមក លើការប្រើប្រាស់សៀវភៅការអប់រំស្តីពី ការប្រឆាំងអំពើពុករលួយ កម្រិត មធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ ទី១១ និងថ្នាក់ទី១២នេះ។

**៥.ការវាយតម្លៃ**

ការវាយតម្លៃត្រូវធ្វើទៅតាមលំនាំការវាយតម្លៃរបស់មុខវិជ្ជា សីលធម៌-ពលរដ្ឋវិជ្ជា ហើយពិន្ទុត្រូវបូកបញ្ចូលជាពិន្ទុមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជាតែមួយ ។

ទទួលបានសេចក្តីណែនាំនេះ សូមឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធានអង្គភាពក្រោមឱវាទទីស្តីការក្រសួង និងលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាត់ចែងអនុវត្ត ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីឆ្នាំសិក្សា២០១៤-២០១៥ នេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែ មករា ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងមុខងារសាធារណៈ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាលារាជធានី ខេត្ត
-អង្គភាពក្រោមឱវាទទីស្តីការក្រសួង អយក
-មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
"ដើម្បីសហការអនុវត្ត"
-ឯកសារ-កាលប្បវត្តិ នា អកស